# ២៥- អ្នកតា តាលាក់

ប្រជុំរឿងព្រេងខ្មែរភាគ ៨ ពីទំព័រទី ១៨៣ – ១៨៥

---

នៅក្នុងឃុំគៀនជ្រៃ ស្រុកកំពង់សៀម (កំពង់ចាម) ឮគេជំណាលថា កាលដែលស្រុកខ្មែរកើតវិបរិតជាមួយនឹងចាម ទ័ពខ្មែរមានជ័យជម្នះបានដេញទ័ពចាមខ្ចាត់ខ្ចាយអស់ ។ មេទ័ពចាមមួយ បានភៀសខ្លួនចូលទៅក្នុងពួនក្នុងព្រៃអំពៅ ដោយអត់អាហារយូរថ្ងៃពេក ក៏ស្លាប់នៅទីនោះទៅ តែដោយកំហឹងគំនុំគំកួននឹងបច្ចាមិត្តខ្លាំងពេក ក៏កើតជាអ្នកតាមួយពូកែអស្ចារ្យ ។ លុះអ្នកស្រុកដឹងថាមានអ្នកតាពូកែ ក៏ធ្វើរោងក្បឿងមួយខ្ទង់គ្របលើផ្នូរអ្នកតា លាក់ ។ តាលាក់ នេះ គាត់ធ្វើតែអ្នកណាដែលស៊ីសាច់ជ្រូក ព្រោះគាត់ចាម ដូច្នេះអ្នកស្រុកគៀនជ្រៃ ប៉ែកខាងជើងព្រែកទាំងមូល មិនហ៊ានយកសាច់ជ្រូកចូលទៅក្នុងស្រុកភូមិទេ បើមានបុណ្យទានអ្វី ប្រើតែសាច់គោនិងប្រេងប៉ុណ្ណោះ ។ ពីឆ្នាំ ១៩៣៦ ឬ ៣៧ មានឈ្មោះ ហ៊ុល ហេន នៅស្រុកស្ទឹងត្រង់ កំពង់ចាម បានទិញឡានមួយយកទៅរត់ឈ្នួលឯស្ទឹងត្រង់ បើកឡានទៅដល់រោងតាលាក់ ក៏ចុះទៅបន់សុំឲ្យជួយ ឲ្យបានចម្រើនក្នុងរបររត់ឡាននេះ និងថ្វាយទេសឯកប្រវែងផ្នូរ ហើយក៏ចេញឡានទៅ ។ យប់នោះឯងតាលាក់ទៅពន្យល់សប្តិ ហ៊ុល ហេន ថា "អញមករក្សាឡានឲ្យហើយ តែកុំទទួលដាក់សាច់ជ្រូកឲ្យសោះ" ។

ពីរបីខែដំបូង ហ៊ុល ហេន មិនហ៊ានទទួលដាក់អ្នកជិះឯណាដែលមានសាច់ជ្រូកសោះ រកស៊ីឃើញចំណេញគ្រាន់ទប់ទល់ តៗមកម្ចាស់ឡានចេះតែលួចដាក់សាច់ជ្រូកបន្តិចៗ ឡានចេះតែខូច បែកកង់ ខូចម៉ាស៊ីនមួយថ្ងៃធ្លាប់រត់បានបីជើង ទៅជាមិនបានមួយជើងផងក៏មាន ខាតៗទៅទាល់តែរកស៊ីលែងបាន ។ ម្យ៉ាងទៀត តាលាក់នេះពីដើមនៅក្បែរមាត់ទន្លេទេ លុះដីបាក់ជិតៗមក ក៏ស្រាប់តែឃើញផ្នូរគាត់ ទៅនៅឯកណ្តាលចម្ការ ឆ្ងាយពីមាត់ទន្លេទៅវិញ អ្នកស្រុកក៏រើរោងតាមទៅ ។

នៅឃុំគៀនជ្រៃ គួរឲ្យសើចណាស់ ត្រើយព្រែកម្ខាង អ្នកស្រុកបរិភោគសាចជ្រូក ត្រើយម្ខាងបរិភោគមិនបាន ជនឯណាចចេសនឹងបានចុកពោះមិនខាន ។

## ក្បួនហៃអ្នកតា

ពីល្ងាចសូត្រមន្ត ព្រឹកឡើងប្រគេនចង្ហាន់ដល់ព្រះសង្ឃ រួចហៃបាយ ព្រលឹងទៅសុំពរសព្ទសាធុការពីអ្នកតាសុំឲ្យមានទឹកភ្លៀងបរិបូណ៌ ធ្វើស្រែចម្ការឲ្យបានល្អ សុំកុំឲ្យមានជំងឺដង្កាត់ និងសុំឲ្យស្រុកបានសុខសាន្តត្រាណជាដើម ។ បាយព្រលឹងនេះ គេយកទៅជូនអ្នកណាដែលធំជាងគេក្នុងខែត្រ មានអភិបាលខែត្រ ឬអភិបាលស្រុកជាដើម ។ តាមទំនៀមដែលឡើងអ្នកតា បើធ្វើតាមទម្លាប់នោះ ត្រូវសង់រោងយ៉ាងអ៊ឹកធឹកណាស់ មានល្បែង របាំ ភ្លេងភ្លាត់ មេឃុំម្នាក់ត្រូវធ្វើរោងរបស់ខ្លួន ។ ម្យ៉ាងទៀត គេត្រូវកាប់ក្របីឃ្លៀចថ្វាយ

អ្នកតាផង ទំនៀមថ្វាយសត្វរស់នេះ មានធ្វើនៅខែត្របាភ្នំ ចំពោះអ្នកតាមេស នៅខែត្រស្នឹងត្រែង ។ល។ ក្នុងស្រុកកំពង់ត្របែក នៅឃុំព្រះធាតុ មានអ្នកតានាងសល្អស្អាត អ្នកតានោះស៊ីតែទន្សាយ ។ អ្នកស្រុកនិយាយថា នៅឱកាសដែលរៀបពិធីឡើងអ្នកតា តែមានទន្សាយរត់ចូលមក ឲ្យចាប់សម្លាប់ថ្វាយអ្នកតាភ្លាម ឥឡូវនេះគេបានយកជ្រូកជំនួសទន្សាយវិញ ។

## តង្វាយអ្នកតា

អ្នកតាទាំងអស់លើកលែងតា លាក់ និងយាយ ទេពចេញសុទ្ធតែត្រូវការក្បាលជ្រូកទាំងអស់ ចំណែកតា លាក់ និងយាយ ទេព ត្រូវការបាយដំណើប ប្រហុកអាំង សំពត់ស ក្លស់ ទៀន ធូប ។ អ្នកតាឯទៀតត្រូវការសំណែនជាបាយម្ហូបស្រាក៏មាន ចេកស្លាធម៌ក៏មាន ។ល។